អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតទៅលើអត្ថបទមួយដែលមានចំណងជើងថា «ការពិចារណាផ្អាកសំណុំរឿងនានានៅសាលាក្តីខ្មែរក្រហម» ដែលចេញផ្សាយលើទំព័រកាសែតភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧

សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានកត់សម្គាល់ទៅលើអត្ថបទ កាសែត ភ្នំពេញ ប៉ុស្តិ៍ ដែលបានបញ្ជាក់ជូនខាងលើ ហើយបានសម្រេចជូនដំណឹងដល់សាធារណជនដោយផ្ទាល់ ដើម្បីបញ្ចៀសនូវការស្មាន ដោយផ្អែកទៅលើអង្គហេតុមិនត្រឹមត្រូវ ជាពិសេសដោយសារតែភាគីខ្លះបានលើកឡើងយ៉ាងច្បាស់ ឬដោយប្រយោលរួចហើយជាមួយកាសែតនេះអំពីអត្ថិភាពនៃសេចក្តីសម្រេច។

សហចៅក្រមស៊ើបអង្កេតបានស្នើឲ្យភាគីដាក់សេចក្តីសន្និដ្ឋានសម្រាប់សំណុំរឿង ០០៣, ០០៤ និង ០០៤/២ និងការិយាល័យរដ្ឋបាលរបស់តុលាការ ដោយបានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនអំពីស្ថានភាពថវិកាសម្រាប់សាលាក្តី និងផលប៉ះពាល់នៃស្ថានភាពថវិកានេះចំពោះអនាគតនៃសំណុំរឿងទាំងនេះ។

សំណើនេះត្រូវបានផ្ញើជូនដោយសម្ងាត់ ពីព្រោះនេះ គឺជាផ្នែកមួយនៃដំណាក់កាលស៊ើបអង្កេត ដែលជាទូទៅត្រូវតែរក្សាការសម្ងាត់ ហើយម្យ៉ាងទៀត ពីព្រោះតែបញ្ហានេះមានភាពរសើបខ្លាំង ការិយាល័យរដ្ឋបាលនឹងត្រូវពិគ្រោះជាមួយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាពាក់ព័ន្ធនឹងថវិកានេះ។ នេះជាបញ្ហារសើប និងមិនត្រូវយកមកពិភាក្សាជាសាធារណៈនៅក្នុងដំណាក់កាលនេះទេ។

អត្ថបទកាសែតនេះក៏មិនត្រឹមត្រូវដែរ ដោយសារតែ ទី១ នេះជាសេចក្តីសម្រេចរួមរបស់សហចៅក្រមទាំងពីរ ដូច្នេះ ជាការមិនត្រឹមត្រូវទេដែលលើកឡើងថា ខ្លឹមសារ និងសំអាងហេតុនៃសេចក្តីសម្រេចនេះ ចេញតែពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯងនោះ។ ទី២ ពុំមាន "សេចក្តីសង្ខេបផ្លូវការ" នៃសេចក្តីសម្រេចនេះទេ។ កាសែតភ្នំពេញប៉ុស្តិ៍ដកស្រង់ពាក្យពេចន៍ដើមនៃឯកសារ ឬសម្រង់ដែលអ្នករាយការណ៍បានផ្តល់ជូន។ ព័ត៌មាននេះបានលេចធ្លាយ ដោយរំលោភលើកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់របស់អ្នករាយការណ៍ និងជាការរំលោភលើទំនុកចិត្តវិជ្ជាជីវៈយ៉ាងធ្ងន់ធ្ងរ និងគួរឲ្យសោកស្តាយ។ សហចៅក្រមស៊ើបអង្កេតពុំមានមតិយោបល់អ្វីទៀតទេលើបញ្ហានេះ៕

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh